YUNNAN DAILY PRESS GROUP
No.142

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 26 លេខ 7551 ថ្ងៃសុក្រ ទី 02 ខែ កុម្ភៈ ឆ្នាំ 2018

## ខេត្តយូនណានជំរុញការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ



*ស្ពាន បៃប៉ានជៀង (Baipanjiang) គឺជាស្ពានដែលកសាងនៅរយៈកម្ពស់ ៥៦៥ ម៉ែត្រនៅពីលើទន្លេបានប៉ាន (Banpan) ដោយមានបណ្តោយ ១.៣៤១,៤ ម៉ែត្រ ដោយភ្ជាប់ទីក្រុង ស៊្វនវៃ (Xuanwei) នៅខេត្តយូណាន ទៅស្រុកស៊ុយចេន (Shuicheng) នៅក្នុងទីក្រុង ជីចូវ (Guizhou) ដោយស្ពាន នេះជាស្ពានមានរយៈកម្ពស់ខ្ពស់ជាងគេ បំផុតនៅលើពិភពលោក ( រូបថត ដោយ Sun Xiao Yun )*

ក្នុងគោលបំណងនៃការជំរុញការអភិវឌ្ឍន៍ដោយល្បឿនលឿនខេត្តយូនណានបានកំណត់និងដំណើរការអនុវត្តផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរយៈពេល៥ឆ្នាំ ។ តាមផែនការដែលបានកំណត់ខេត្តយូនណាននឹងបណ្តាក់ទុនវិនិយោគ ១,៦ទ្រីលានយ៉ន ដើម្បីពន្លឿនការសាងសង់ប្រព័ន្ធបណ្តាញផ្លូវថ្នល់បណ្តាញបង្ហូរទឹក ផ្លូវអាកាសបណ្តាញអ៊ីនធើណែត និងបណ្តាញផ្គត់ផ្គង់ថាមពល ។

ក្នុងឆ្នាំ២០១៧ ខេត្តយូនណានបានសាងសង់និងដាក់ឱ្យប្រើប្រាស់នូវផ្លូវល្បឿនលឿនចំនួន១២ខ្សែ ។ ក្នុងចំណោមគម្រោងចំនួន៨២ ដែលបានកំណត់ក្នុង "ផែនការអភិវឌ្ឍន៍រយៈពេល៥ ឆ្នាំទី ១៣" មានគម្រោងចំនួន៧ បានត្រូវបញ្ចប់ការអនុវត្តជាស្ថាពរដោយបានសាងសង់ផ្លូវថ្នល់ប្រវែង ៤៥១គីឡូម៉ែត្រ ។ ក្រៅពីនេះគម្រោងសាងសង់ផ្លូវដែកយូស៊ី-ម៉កហានផ្លូវដែកតាលី-យូយលីនិងគម្រោងសាងសង់ផ្លូវដែកចំនួន១១ទៀតបានត្រូវដំណើរការអនុវត្តដោយរលូន ។

ក្នុងអំឡុងពេលពីខែមករាដល់ខែតុលាឆ្នាំ ២០១៧ ខេត្តយូនណានបានបណ្តាក់ទុនវិនិយោគសរុប៥៧.០១១ លានយ៉ន់ប្រាក់ចិនលើគម្រោងអចលនទ្រព្យប្រព័ន្ធធារាសាស្ត្រកើនឡើង ៣៤,៤៦ ភាគរយ ស្មើនឹង១៤.៦០០ លានយ៉ន ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៦ ។ គម្រោងបង្ហូរទឹកនៅភូមិភាគកណ្តាលនៃខេត្តយូនណានបានបើកការដ្ឋានសាងសង់នៅខែសីហាឆ្នាំ២០១៧ ដែលជានិមិត្តសញ្ញា នៃការពន្លឿនដំណើរសាងសង់ប្រព័ន្ធបណ្តាញបង្ហូរទឹកនៃខេត្តយូនណាន ។

បើនិយាយអំពីវិស័យសាងសង់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនតាមផ្លូវអាកាសមានអ្នកដំណើរ ៣១,៩២លាននាក់ធ្វើដំណើរឆ្លងកាត់ព្រលានយន្តហោះខេត្តយូនណាននៅឆ្នាំ២០១២ ចំណែកនៅឆ្នាំ ២០១៧ ព្រលានយន្តហោះខេត្តយូនណានបានទទួលអ្នកដំណើរ៦៣ លាននាក់ កើនឡើងជាងទ្វេដងធៀបនឹងឆ្នាំ ២០១២ ។ ម្យ៉ាងទៀតព្រលានយន្តហោះតូចៗមួយចំនួនធំនៅខេត្តយូនណានបានត្រូវអភិវឌ្ឍន៍ឱ្យបានកាន់តែល្អប្រសើរដែលបានធ្វើឱ្យទីផ្សារអាកាសចរណ៍នៃខេត្តយូនណានទទួលបានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។

នៅលើវិស័យសាងសង់បណ្តាញផ្គត់ផ្គង់ថាមពលខេត្តយូនណានបានខិតខំជំរុញការសាងសង់ស្ថានីយវារីអគ្គិសនីមួយចំនួន ។ ផ្នែកក្រុងលីជាំងនិងក្រុងយូយលី នៃគម្រោងសាងសង់បំពង់បញ្ជូនឧស្ម័នធម្មជាតិចិន-មីយ៉ាន់ម៉ាបានត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។ ទន្ទឹមនឹងនេះដោយសារប្រព័ន្ធផ្គត់ផ្គង់ថាមពលបៃតងបានត្រូវដំណើរការអនុវត្តដោយរលូនខេត្តយូនណានបានជំរុញការវិនិយោគនិងអភិវឌ្ឍន៍ថាមពលស្អាតមួយចំនួន ដូចជាថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យកម្លាំងខ្យល់ ឬ PV ជាដើម ។

នៅលើវិស័យបណ្តាញអ៊ីនធើណេត ខេត្តយូនណានបានសាងសង់បណ្តាញខ្សែកាបអុបទិកដែលមានគុណភាពខ្ពស់និងបានគ្របដណ្តប់លើតំបន់ដ៏ច្រើន ។ សព្វថ្ងៃខ្សែកាបអុបទិកបានគ្របដណ្តប់លើភូមិចំនួន៩៨ភាគរយក្នុងខេត្តយូនណានចំណែកបណ្តាញសេវាទូរស័ព្ទចល័ត4G បានគ្របដណ្តប់លើទីក្រុងនិងភូមិទាំងអស់នៅខេត្តយូនណាន ។ ការរីកចម្រើននៃ ហេដ្ឋារចនាសម្ព័ន្ធបានផ្តល់សេវាកម្មកាន់តែល្អប្រសើរ និងពេញលក្ខណៈដល់ប្រជាជននៅខេត្តយូនណាន ៕

**ដោយលី ឈីងហាន**

## យូនណានសម្រេចទំហំពាណិជ្ជកម្មជាង ៨១,១ ពាន់លាន យ៉ន់ ជាមួយ ប្រទេស ទន្លេមេគង្គទាំងប្រាំនៅឆ្នាំ២០១៧

តាមដំណឹងពីស្ថាប័នគយនៃក្រុងគុនមីង បានឱ្យដឹងថា នៅឆ្នាំ ២០១៧ ខេត្តយូនណានបានសម្រេចនូវទំហំពាណិជ្ជកម្ម ៨១១,៧០ លានយ៉ន់ជាមួយប្រទេសនៅតាមបណ្តោយដងទន្លេមេគង្គទាំងប្រាំ រួមមានប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម កើនឡើង១៣,៤ភាគរយ ។

នៅខែមីនាឆ្នាំ២០១៦ យន្តការស្តីពីកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គបានត្រូវដំណើរការអនុវត្តន៍ជាផ្លូវការ។ បន្ទាប់ពីនោះស្ថាប័នគយនៃក្រុងគុនមីងបានរៀបចំសកម្មភាពផ្លាស់ប្តូរគ្នាជាច្រើនប្រភេទជាមួយស្ថាប័នគយនៃបណ្តាប្រទេសនានា ដូចជាកិច្ចប្រជុំពិភាក្សាការងារការផ្លាស់ប្តូរទស្សនកិច្ច និងការផ្លាស់ប្តូរផ្នែកវប្បធម៌ជាដើម ក្នុងនោះរួមមានកិច្ចប្រជុំពិគ្រោះពិភាក្សាអំពីច្រកផ្លូវអន្តរជាតិគុនមីង-បាងកក (ចិន-ឡាវ-ថៃ) កិច្ចប្រជុំអ្នកទំនាក់ទំនងគយប្រទេសទន្លេឡានឆាង-មេគង្គនិងកិច្ចប្រជុំពិភាក្សាការងារគយចិន-ឡាវជាដើម។ កិច្ចប្រជុំទាំងនេះបានជំរុញការបង្កើតយន្តការថ្មី និងបានរក្សាទំនាក់ទំនងជាអចិន្ត្រៃយ៍រវាងស្ថាប័នគយនៃបណ្តាប្រទេសពាក់ព័ន្ធក្នុងតំបន់ទន្លេឡានឆាង-មេគង្គ៕

## អ្នកកាសែតខ្មែរៈពិព័រណ៍ចិន-អាស៊ីខាងត្បូង បង្ហាញពីការរីកចម្រើននៃខេត្តយូនណាន



*លោកមាស សំអុល រូបទីមួយពីខាងឆ្វេងកំពុងសំភាសន៍ លោក ស៊ុន ចាន់ថុល កាលលោកនៅជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៅក្នុងអំឡុងពិពណ៌ពិព័រណ៍ចិន-អាស៊ីខាងត្បូងដែលរៀបចំនៅក្នុងទីក្រុងគុនមិញ កាលពីឆ្នាំ២០១៥ ( រូបថតដោយ Liu Rong )*

លោកមាស សំអុល អ្នកកាសែតនៃទីភ្នាក់ងារសាព័ត៌មាន AKP ប្រទេសកម្ពុជាបានប្រាប់អ្នកកាសែតចិនថា នៅឆ្នាំ២០១៦លោកធ្លាប់ទៅបំពេញទស្សនកិច្ចនៅខេត្តយូនណាន ដើម្បីយកបទសម្ភាសន៍អំពីពិព័រណ៍ចិន-អាស៊ីខាងត្បូងលើកទី៤ ។ តាំងពីពេលនោះមកលោកបានមានអារម្មណ៍ជិតជាប់ជាមួយខេត្តយូនណាន ហើយមិនដែលភ្លេចខេត្តដ៏ស្រស់ស្អាតនេះសោះឡើយ។

លោកបានបញ្ជាក់ថា ពិព័រណ៍ចិន-អាស៊ីខាងត្បូងបានទាក់ទាញអ្នកនយោបាយសហគ្រិនអ្នកជំនាញការនិងអ្នកសារព័ត៌មានដ៏ច្រើនដែលមកពីប្រទេសអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍។ ក្នុងពិព័រណ៍នេះប្រទេសផ្សេងៗបានដាក់តាំងបង្ហាញនូវផលិតផលពិសេសរបស់ខ្លួន ។ ជាពិសេសបច្ចេកវិទ្យាទំនើបនិងផលិតផលថ្មីមួយចំនួនធំរបស់ខេត្តយូនណានបានទាក់ទាញក្រសែភ្នែករបស់អ្នកទស្សនា ដែលមកពីបណ្តាប្រទេសនានាលើពិភពលោក ។ លោកបន្តទៀតថា ខ្ញុំបានស្គាល់មិត្តល្អច្រើនដែលមកពីបណ្តាប្រទេសនានាក្នុងឱកាសពិព័រណ៍ចិន-អាស៊ីខាងត្បូងនេះជាពិសេសខេត្តយូនណានជាខេត្តមួយដែលមានទេសភាពស្រស់ស្អាតមានលក្ខណៈបើកទូលាយនិងប្រកបទៅដោយបរិយាបន្ន ។ បច្ចុប្បន្នយូនណានជាខេត្តអន្តរជាតិល្បីឈ្មោះមួយលើពិភពលោកចំណែកពិព័រណ៍ចិន-អាស៊ីខាងត្បូងបានបង្ហាញពីការរីកចម្រើនយ៉ាងឆាប់រហ័សរបស់ខេត្តយូនណាន ។

សព្វថ្ងៃ ខេត្តយូនណានកំពុងចូលរួមយ៉ាងសកម្មក្នុងការស្ថាបនា "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ព្រមទាំងខិតខំប្រឹងប្រែងដើម្បីក្លាយទៅជាមជ្ឈមណ្ឌលនាំផ្លូវ អភិវឌ្ឍន៍នៃតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។ លោកមាស សំអុល បានលើកមតិថា ខេត្តយូនណានមានទីតាំងភូមិសាស្ត្រដ៏មានឧត្តមភាពសម្រាប់ការចូលរួមកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ ពីព្រោះទន្លេឡានឆាង-មេគង្គ បានតភ្ជាប់ខេត្តយូនណានទៅនឹងប្រទេសទន្លេមេគង្គទាំងប្រាំ ។ មិនតែប៉ុណ្ណោះ ខេត្តយូនណានមានធនធានធម្មជាតិដ៏សម្បូរ និងមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅមក ។ ជាពិសេសប៉ុន្មានឆ្នាំនេះបណ្តាញអ៊ីនធឺណេតនៃខេត្តយូនណានបានទទួលការរីកចម្រើនច្រើនគួរឱ្យកត់សម្គាល់។ ចំណុចទាំងនេះបានចាក់បញ្ចូលកម្លាំងចលករថ្មីសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ខេត្តយូនណាន។

លោកបានសង្កត់ធ្ងន់ថា ទន្ទឹមនឹងការរីកចម្រើននៃទំនាក់ទំនងកម្ពុជានិងចិនមានសហគ្រាសខេត្តយូនណានកាន់តែច្រើនទៅធ្វើវិនិយោគនៅក្នុងប្រទេសកម្ពុជា។ តាមរយៈសហគ្រាសទាំងនេះមានប្រជាជនខ្មែរកាន់តែច្រើនស្គាល់ខេត្តយូនណាន។ សព្វថ្ងៃប្រជាជនខ្មែរអាចទិញបានផ្កាស្រស់និងបន្លែបង្ការ ដែលនាំចូលពីខេត្តយូនណានហើយក៏អាចរកហូបគុយទាវខេត្តយូនណាននៅទីក្រុងភ្នំពេញបានដែរ។ លោកបានបន្ថែមដោយមានភាពសប្បាយរីករាយថានេះជារឿងដែលគេគិតមិនដល់ពីមុន។

លោកបានសម្តែងនូវក្តីសង្ឃឹមរបស់ខ្លួនថាទន្ទឹមនឹងការពន្លឿនដំណើរកសាង "ខ្សែក្រវាត់មួយ និងផ្លូវមួយ" កិច្ចសហប្រតិបត្តិការកម្ពុជានិងចិននឹងអាចទទួលបានសមិទ្ធផលជាក់ស្តែងកាន់តែច្រើនថែមទៀត។ ក្នុងនាមជាអ្នកកាសែតម្នាក់ ខ្ញុំពិតជាមានភាពសប្បាយរីករាយ ដែលនឹងអាចមានឱកាសទៅយកបទសម្ភាសន៍នៅខេត្តយូនណានក្នុងឱកាសពិព័រណ៍ចិន-អាស៊ីខាងត្បូងដើម្បីឧទ្ទេសនាមជូនមិត្តអ្នកអានខ្មែរអំពីកាលានុវត្តភាពថ្មីសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកម្ពុជានិងចិន ៕

## "កង់ចែករំលែកគ្នា" របស់ប្រទេសចិនបង្ហាញខ្លួននៅប្រទេសឥណ្ឌា



*នៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៨ សិស្សម្នាក់នៅសាលា ស្ត្រីមួយក្នុងក្រុងញូវដេលីនៃប្រទេសឥណ្ឌាកំពុងស្កេនបាកូដ ដើម្បីប្រើប្រាស់ "កូនកង់ពណ៌លឿង" របស់ក្រុមហ៊ុន ofo (រូបថត ដោយ Zhang Naijie របស់ (Xinhua)*

តាមការឧទ្ទេសនាមពីអ្នកទទួលខុសត្រូវនៃក្រុមហ៊ុនកង់ចែករំលែកគ្នា ofo ប្រទេសចិនបានឱ្យដឹងថា កង់ចែករំលែកគ្នា ofo (កង់សាធារណៈ) របស់ប្រទេសចិនដែលគេនិយមចូលចិត្តហៅថា "កូនកង់ពណ៌លឿង" នោះ បានត្រូវសាកល្បងប្រើប្រាស់នៅទីក្រុងចំនួនប្រាំពីរនៃប្រទេសឥណ្ឌា រួមមានក្រុង ញូវដេលី, អ៊ីនឌ័រ បឹងហ្គាឡូ, អាហ្មេដាបាត, ពូនណា, កូអ៊ីមបាទ័រ , និងចេនណៃ ។ សព្វថ្ងៃ ក្រុមហ៊ុន ofo បានដាក់កង់ចែករំលែកគ្នា៣.០០០គ្រឿងនៅប្រទេសឥណ្ឌាសម្រាប់ឱ្យប្រជាជនឥណ្ឌាប្រើប្រាស់ ៕

**ដោយចាំង ណៃជា (ស៊ីន ហួចិន)**

## មូលដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ ទន្លេឡានឆាង-មេគង្គបណ្តុះបណ្តាល សិក្ខាកាមបរទេសជាងមួយម៉ឺននាក់

តាមដំណឹងពីសាកលវិទ្យាល័យជនជាតិខេត្តយូនណានបានឱ្យដឹងថា គិតមកដល់ខែមករា ឆ្នាំ២១០៨ មជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាលចិន-អាស៊ាន ដែលជាផ្នែកសំខាន់មួយនៃមូលដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈទន្លេឡានឆាង-មេគង្គនោះបានបណ្តុះបណ្តាលសិក្ខាកាមបរទេសជាង ១១.៨០០នាក់ ដែលមកពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។ គួរបញ្ជាក់ថា វគ្គបណ្តុះបណ្តាលបានត្រូវរៀបចំនៅមូលដ្ឋានបណ្តុះបណ្តាលចំនួនប្រាំពីរ នៅក្នុងក្រុងយូយលី ស្រុកម៉ាលីភ្វូ ស្រុកម៉ឹងឡាស្រុកម៉ឹងលាន ក្រុងលីនឆាង ស្រុកជិនខាង និងស្រុកឆាងយាន់ចំណែកសិក្ខាកាម ដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាលទាំងនោះសុទ្ធតែជាជនបរទេសដែលមកធ្វើការនៅប្រទេសចិនពីប្រទេសទន្លេមេគង្គទាំងប្រាំ ។

នៅខែធ្នូ ឆ្នាំ២០១៧ មូលដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈទន្លេឡានឆាង-មេគង្គ ដែលបង្កើតដោយសាកលវិទ្យាល័យជនជាតិខេត្តយូនណានបានសម្ពោធស្លាកជាផ្លូវការនៅក្រុងគុនមីង។ មជ្ឈមណ្ឌលអប់រំនិងបណ្តុះបណ្តាលចិន-អាស៊ាន ជាស្ថាប័នសំខាន់មួយ នៃមូលដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈទន្លេឡានឆាង-មេគង្គនេះ។ ឈរលើមូលដ្ឋាននៃមជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាលនេះសាកលវិទ្យាល័យជនជាតិខេត្តយូនណានបានបង្កើតមហាវិទ្យាល័យបណ្តុះបណ្តាល វិជ្ជាជីវៈអន្តរជាតិដើម្បីបណ្តុះបណ្តាលធនធានមនុស្សដែលមានគុណភាពខ្ពស់ដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេសទន្លេឡានឆាង-មេគង្គ៕ **ដោយហាន ឈីងយាន់**